# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២០ ខែ មិនា ឆ្នាំ២០១៥

## ជប៉ុនផ្តល់ថវិកាសរុបចំនួន១៩២,៧៤៦ ដុល្លារអាមេរិក សម្រាប់ការអនុវត្តគម្រោងផ្នែកសុខភាពចំនួនពីរ

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាសរុបចំនួន ១៩២,៧៤៦ ដុល្លារអាមេរិក ដល់មន្ទីរសុខាភិបាលខេត្តតាកែវ និងមន្ទីរសុខាភិបាលខេត្តក្រចេះ។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងពីរសម្រាប់គម្រោងដូចតទៅ៖

១. <u>គម្រោងសាងសង់អគារជម្ងឺទូទៅមួយខ្នងនៅមន្ទីរពេទ្យរងរមេញ នៃមន្ទីរពេទ្យបង្អែកគិរីវង់ ខេត្តតាកែវ (ថវិកាចំនួន ១០៣,០៨២ ដុល្លារអាមេរិក)</u>

<u>អង្គភាពទទួលជំនួយ៖ មន្ទីរសុខាភិបាលខេត្តតាកែវ</u>

ជាមួយនឹងគោលបំណងនៃការធានាកន្លែងសម្រាប់ស្នាក់នៅជូនដល់អ្នកជម្ងឺនៅមណ្ឌលសុខភាពក្នុងស្រុក មន្ទីរសុខាភិបាលខេត្តតាកែវ នឹងសាងសង់នូវអគារជម្ងឺទូទៅចំនួនមួយខ្នង និង បំពាក់ទៅដោយគ្រែសម្រាប់អ្នកជម្ងឺចំនួន ២១ នៅក្នុងមន្ទីរពេទ្យរងរមេញ នៃមន្ទីរពេទ្យបង្អែកគិរីវង់។ គម្រោងនេះត្រូវបានរំពឹងថា នឹងការពារអ្នកជម្ងឺពីការឆ្លងមេរោគនៅមន្ទីរពេទ្យ និងផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រល្អប្រសើរជាងមុនជូនដល់ប្រជាពលរដ្ឋប្រមាណជា ១៨,៧០០នាក់ នៅក្នុងតំបន់។

២. <u>គម្រោងសាងសង់មណ្ឌលសុខភាពកំពង់ចាម ក្នុងស្រុកសំបូរ ខេត្តក្រចេះ (ថវិកាចំនួន ៨៩,៦៦៤ដុល្លារអាមេរិក)</u>

<u>អង្គភាពទទួលជំនួយ៖ មន្ទីរសុខាភិបាលខេត្តក្រចេះ</u>

ដើម្បីអោយប្រជាជននៅមូលដ្ឋានទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រល្អប្រសើរជាងមុន មន្ទីរសុខាភិបាលខេត្តក្រចេះ នឹងសាងសង់មណ្ឌលសុខភាពមួយខ្នងនៅក្នុងឃុំ។ គម្រោងនេះ ត្រូវបានប៉ាន់ស្មានថា ប្រជាពលរដ្ឋប្រមាណ ១០,០០០នាក់នៅក្នុងតំបន់ នឹងទទួលបានការថែទាំសុខភាព។

*ជំនួយឥតសំណង គូសាណូណិ របស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្ថាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៣លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៣០ គម្រោងនៅទូទាំងប្រទេស។





ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp